## កិច្ចការឬយុត្តាធិការក្នុងស្រុក (domestic jurisdiction)

មាត្រា២(៧) រដ្ឋធម្មនុញ្ញនៃអង្គការសហប្រជាជាតិ (UN Charter) ចែងអំពីរឿងនេះ ក្នុងន័យហាមឃាត់មិនឲ្យមានការជ្រៀតជ្រែកការងារក្នុងស្រុករបស់រដ្ឋ (intervene in matters which are essentially within domestic jurisdiction of any State)។ ទោះបីជាយ៉ាងនេះក្តី វាមានករណីលើកលែង ចំពោះសកម្មភាពអនុលោមតាមជំពូកទី៧ នៃធម្មនុញ្ញនេះ ដែលអនុញ្ញាត ឲ្យអង្គការសហប្រជាជាតិ ជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងនៃរដ្ឋណាមួយ។

មាត្រា២(៧) មានមូលដ្ឋានពីកតិកាសញ្ញា League of Nations ហើយតាមការអនុវត្ត ការជ្រៀតជ្រែក ត្រូវបានបកស្រាយតឹងរឹង សំដៅការជ្រៀតជ្រែកដោយបំពាន (dictatorial interference) នាំដល់ទៅការបដិសេធនូវឯករាជ្យភាពរបស់រដ្ឋ។

អ្វីទៅជាកិច្ចការងារផ្ទៃក្នុងរបស់រដ្ឋ គឺជាអ្វីដែលមិនមានចែងដោយច្បាប់អន្តរជាតិ។ អ្វីដែលពីមុនជាកិច្ចការក្នុងស្រុក (ការប្រព្រឹត្តដោយអាជ្ញាធររដ្ឋលើប្រជាពលរដ្ឋខ្លួន) លែងស្ថិតនៅក្នុងវិសាលភាពនៃកិច្ចការងារក្នុងស្រុកទាំងស្រុងហើយ ហើយបានអាចក្លាយជាកិច្ចការងារក្នុងសមត្ថកិច្ចអន្តរជាតិ។ កិច្ចការងារទាំងនោះដូចជា បញ្ហាសិទ្ធិមនុស្ស សកម្មភាពដែលបង្កើតជាការគម្រាមកំហែងសន្តិភាព កាតព្វកិច្ចមានចរិតអន្តរជាតិ។

**ខ្លឹមសារបន្ថែម៖** ការសម្រេចផ្តល់សញ្ជាតិដល់បុគ្គលណាមួយ គឺជាកិច្ចការងារក្នុងស្រុករបស់រដ្ឋ។